In response to the request to supply water in the five tartget provinces, a study team was set up to carry out the groundwater development since December 1996.

During the JICA program has been implemented, it was the establishment of health and hygiene education strategy. Water and sanitation can reduce many types of diseases and improve the poor people's living conditions in the rural area.

Scope

This document describes the process of water and hygiene education of the water supply program which was developed to optimize the benefits of the clean drinking water supply. There are three types education of the process including social education for community mobilisation, water use and hygiene education, and technical education of caretaker for the operation and maintainance of the water bases.

I. The water sector in Cambodia

In Cambodia, the people generally depends on surface water from pond (private and public), irrigation canal, rivers and shallow wells or catch rainwater for domestic use. Ponds are dug or re-dug as the water reservoir before the rainy season. Rainwater is the people's favourite source for drinking.

The rainy season starts from May and lasts November. For the reason of the dry season, many ponds and other sources are dried up and creating a water shortage. Therefore, people have to get water and start relying on other sources (hand pump wells or buying water).

According to the field survey and observation of the water quality, they show us that most of traditional water sources are the contaminated water used by the local people. Ponds, rivers and canals are used for all different demands including bathing, washing clothes, animals and so on. Open wells are rarely protected without cover and water traction system. Villagers take water individually by buckets, which is causing the water pollution.

II. Water-related health problem

Some of the major diseases in developing countries are related with water and sanitation. There are ten diseases that they take into account primary water and sanitation interventions for preventions: diarrhea, typhoid, ascariasis, giardiasis, hookworm, hepatitis (A, E), schistosomiasis, amebiasis, trichuriasis and dracunculiasis. These ten diseases cause a tremendous amount of illness every year, the big killer among them was diarrheal disease.

Although it is important to know as much as possible about the etiology of water and sanitation to all should be focused on health not on disease. Water and sanitation and hygiene education intervention aim to maintain people in a state of health. They ultimately enable children, not just to surrive one illness after and other, but to go to school and get the full benifit of an education by not having worms, by not losing days because of dracunculiasis or malaria, and by not suffering from chronic diarrheal episodes.

*Water-related disease in Cambodia

According to the reseach of JICA, data and other documents were made by non-governmental organizations as well as government organizations. The water born diseases are the major problem due to the lack of hygiene and health education in rural areas. This is a reason why the water supply program, hygiene and health education have been formed and carried out for the community where people do not understand about them.

These diseases are always accured today, most of them are spread by using and drinking unsafe water such as:

1. The disease spread by drinking unsafe water

These types of diseases are dysentery, cholera, typhoid, hepatities (A, E) and parasites. They are spread to the people are using unsafe water without boiling that can be found in the daily life in rural areas.

2. The disease spread by washing cloths and bathing unsafe water

The human health can be affected by using unsafe water for washing cloths and bathing. These types of diseases are skin disease, itch and poxbelly.

3.The disease spread by agent

These types of diseases can be spread from mosquito biting, that can cause malaria, dangue fever and so on. To avoid these diseases, the people must follow the hygiene and health education of the Ministry of Health as well as non governmental organizations on television and radio broadcastings, leaflets and posters relating to the health and hygiene education.

III. Community participation and duty of village water committee

JICA's Water Supply Program in six provinces in southern Cambodia closely cooperated with DRWS to make approvals on the establishment of village water committee and water point committee for taking care of, maintaining and repairing hand pump wells for long term operation after construction. Especially, they seriously concentrate on hygiene and water use education to carry out in the community and to teach the people how to manage the hand-pump well by themselves.

Communities have to follow :

1. **Village Water Committee (VWC)**

   - Chairman (1 person) general respondsibility
   - Secretary (1 person) respondsibility for reports
   - Accountant (1 person) respondsibility for money collection

2- **Water Point Committee (WPC)**

   - Two caretakers responsible for repairing hand pump and platform when it is broken and damaged.
   - And two other caretakers: responsible for taking care, maintenance and transfering these methods of water use education, hygiene education and operation and maintenance.

Table of water-related disease

Name	Module of contamination	Prevention	Signs (= symptom)
Diarrhea	- Contaminated by food, dirty water. - Through patient's dirty material.	- Have to drink safe water or boil before drinking. - Cover food, to avoid insect and well cook. - Clean patient's material	Stool more than 3 times/day, No vomiting,, dry mouth, thirsty, no urine. The soft spot is sagging in wrinkled skin.
Cholera	- Contaminated by food, dirty water. - Through patient's dirty material.	- Have to drink safe water or boil before drinking. - Cover food, to avoid insect and well cook. - Clean patient's material	Profuse watery, mised with white grains like rice, fishy stool, vomit is like stools. It brings out easily. There is cramp, eyes are sunken and look upward. Pluse rapidly beats and there is no urine.
Typhoid	- Contaminated by food, dirty water. - Through patient's dirty material.	- Have to drink safe water or boil before drinking. - Cover food, to avoid insect and well cook. - Clean patient's material	Cramp diarrhea or constipation weakness, headache alway present (or continuous headache). Delirium (person does not think clear or make sense). Arorexia, white tongue
Hepatities A, E	- Contaminated by food, dirty water. - Through patient's dirty material.	- Have to drink safe water or boil before drinking. - Cover food, to avoid insect and well cook. - Clean patient's material	Jaundice Dark yellow urine White stool
Dysenteny	- Contaminated by food, dirty water. - Through patient's dirty material.	- Have to drink safe water or boil before drinkiing. - Cover food, to avoid insect and well cook. - Clean patient's material	Diarrhea with blood, constipation cramp, sickness or poor nutrition lose stool with a lot of mucus.
Polio	Contaminated by water, food	- Have to drink safe water - Don't use patient's material	
Skin diseases Scabies, rige worm	Contaminated by unclean water, bathing, washing	- Have to bath 3 or 4 times/day with the well protecte water. - Steam dress and something for using in family or make it dry in sunshine.	Itch on night time, infection in faulty often. Have other symtom. In this case skin has pus. Place infection pussy, bosom, groin.

Manual for Hygiene Control of Deep Wells with Hand-pumps

MRD/JICA

1. Safe Water and Unsafe Water

Water is hygienically safe for drinking when it does not include any cause of diseases. Dirty water tends to bring about diseases. For example, if drinking water is contaminated by pathogens, it can cause water-borne diseases such as diarrhea, dysentery and typhoid. If the water from personal hygiene is of poor quality and contaminated, it can cause skin problems and infections such as scabies and trachoma.

Generally, adults develop some resistance to these diseases, but children are quite vulnerable and tend to contract them more often than adults. When people can get safe and sufficient water, these diseases will be prevented.

MRD/JICA drilled boreholes and installed hand-pumps so that village people have access to safe and clean water sources.

2. Water Sources and Contamination

There are various water sources in the villages such as rain, rivers, lakes, ponds, dug wells and deep wells. These water sources can be contaminated, but the level of contamination varies from one source to another.

Rainwater is hardly ever contaminated except in industrial areas, where clouds can be affected by air pollution. Pond water is easily contaminated because cows and pigs bathe in it. Lakes are affected by similar conditions, but the velocity of contamination is slower than ponds because the volume of water is larger. Rivers and canals have less contamination than lakes and ponds, because the water flows.

---

1 Water related to infections is classified in terms of their transmission route. Since the impact of water supply improvements on a disease depends on its transmission route, water supplies can be expected to affect the diseases in a given group in a similar way.

Transmission route	Description	Disease group	Examples
1. Water-borne	Transmission by Consumption of contaminated water	Feco-oral (water-borne or water-washed)	Diarrhea, dysentery, typhoid
2. Water-washed	Person-to-person transmission due to lack of water for personal and domestic cleanliness	Skin and eye infections (purely water-washed)	Trachoma, scabies
3. Water-based	Transmission via an intermediate host (e.g. a snail) which lives in water	Water-based	Schistosomiasis
4. Water-related Insect vector	Transmission by insects which breed in water or bite near water	Water-related insect Vector	Malaria, filariasis

Source : Feachem, R. O. (1977). Water supplies for low-income communities: resource allocation, planning and design for a crisis situation. In : Feachem et al. (eds) *water, Wastes and Health in Hot Climates.*_ Chichester : John Wiley and Sons.

THE CAUSE OF DIRTY WATER



TO FENCE AND TO PROTECT HAND PUMP FROM ANIMAL



But if human or animal excreta were dropped upstream, water would be contaminated all the way downstream. Contamination of dug well or deep well is caused by dirty water near the well, which can easily flow into it. However, whereas deep wells are fitted with a tube between the water source and the pump, dug wells are open and shallower than boreholes, and are more easily penetrated by dirty water.

Thus, MRD/JICA strove to drill boreholes. Since they are deeper than hand dug wells by other organizations, their aquifer will not be contaminated easily. However, unless users take preventive measures, there is still a contamination possibility. To prevent this, users will protect safe water source water and the cause of dirty water near the wells.

3. Borehole Contamination Prevention

In order to obtain safe water from the borehole continually, village people must take great care in keeping the hand-pump, the platform and the surroundings clean.

- The hand-pump, the platform and the surroundings must be cleaned every day.
- People must not hang washing out on the hand-pump to dry.
- No garbage should be disposed of on the platform or the surroundings.
- People must not sprinkle dirty water on the surroundings outside the platform.
- If puddles of dirty water appear on the surroundings, the dirty water must be removed and the puddles must be filled up with soil.
- All livestock must be kept away from the hand-pump and the platform.
- No dumping ground or toilet must be set near the hand-pump.
- The drain must not be blocked.
- In case the drain gets blocked, it has to be cleared up.
- People must not do their laundry and bathe within the platform.

4. How to Use Safe Water

If people want to be able to draw safe water from the borehole, they must take care of it in order to keep the water safe. No matter how safe the water may be, if it becomes contaminated it will become unsafe, and can not be turned back into safe water without boiling. Therefore, attention must be paid to the following.

a. Drawing water

- To clean the container for conveying waters (with detergent or ash).
- To check the cleanliness of the hand-pump faucet. If it is dirty, it must be cleaned.

b. Conveying water

- To prevent any waste from entering the water container.
- To use a container fitted with a lid, and make sure to put the lid on when conveying water, if possible.

c. Stocking water

- To wash the jar to stock the water from time to time (with detergent or ash).
- To prevent any waste from entering the jar when the water is poured into it.
- When the water is stocked in the jar, make sure to cover it with the lid so that no waste can enter it.

Don't hang the washing on the hand pump out to dry.
Keep the platform clean at all times.
Don't sprinkle dirty water near the platform.



Keep livestock away from the hand pump and platform.
Don't set up a dumping ground and a toilet near the hand pump.
Don't litter near the platform.



Don’t bathe on or near the platform.



Don’t wash the laundry within the platform.



Wash the container
for conveying water.



Use a container with a lid and
put the lid on the container
when conveying it.

Wash the jar to stock water
occasionally.



Put a lid on the jar,
so that refuse will not enter it.



Use a dipper with a long handle
for ladling water from the jar.



d. Using water

- To use a dipper with a long handle for ladling water out of the jar.
- To rinse the dipper every time before drawing water.
- Not to lift the dipper directly to your lips.
- Not to insert anything into the jar except the dipper (like hands or a cup).

e. Boiling

When there is not enough safe water for consumption, contaminated water can remain safe by boiling to kill the pathogens; the main cause of diseases brought about by water.

Before you drink water and you do not know whether it is safe or not, it is better to boil it and drink water after it has cooled off. If you want a cold beverage with ice, you must make sure that the ice was made from safe water.

f. Filtration

Turbid water and water that contains a lot of iron can be cleaned by filtering. MRD/JICA installed Iron Removal Device on the side of hand-pumps in some villages. This device filters out iron from water through a cloth, gravel and sand filter.

Please pay close attention to the following regarding the public Iron Removal Device.

- Impurities such as iron gradually adhere to the cloth, gravel and sand filter inside the Iron Removal Device. Thus, the cloth, gravel and sand filter must be washed every three months, or replaced when necessary. At that time, put some chlorine into the Iron Removal Device.
- To make sure that no waste enters the Iron Removal Device.
- To keep clean the surrounding of the Iron Removal Device faucet.
- Not to sprinkle any water on the outside of the platform. (Please refers to the Manual for Operation and Maintenance of Deep Wells with Hand-pumps for detailed explanation of the Iron Removal Device.)

Any family can install an Iron Removal Device themselves, because its structure is simple and similar to public Iron Removal Device.

5. Water and Hygiene

When people get enough safe water, they should use it to improve hygiene, which in turn will contribute to improving their health.

As previously mentioned, drinking safe water prevents the spread of diseases brought about by contaminated water. However, diseases can also spread through pathogens attached to dirty hands or tableware. If people do not wash their bodies or their cloths, skin diseases could infect them. Thus, attention must be paid to the following:

- To wash dirty hands.
- To wash hands after going to the toilet.
- To wash hands before a meal.
- To wash dirty tableware.
- To bathe regularly for personal hygiene.
- To wash dirty clothes.

6. Other Environmental Hygiene Consideration

There are other hygiene considerations concerning water as follows.

- To clean all water from sources like rivers, canals, lakes, ponds, dug wells and boreholes.
- Not to defecate and urinate near any water source.
- Not to dump garbage in any water source.
- To burn all combustible garbage, while being careful with fire.
- Not to burn synthetic materials such as plastic and vinyl, as they produce harmful smoke when burning.
- To collect wastes made of synthetic materials in a dumping ground decided by the village chairperson. Because those types of wastes do not rot and turn into soil as organic elements would do, any such as waste that is dumped in the village will remain there and spoil the surrounding beauty.

PICTURE OF IRON REMOVAL DEVICE




PLEASE WASH
YOUR HANDS
BEFORE AND AFTER

A Guide to Personal Hygiene



Problem areas

Hair: dirt sticks more easily to greasy hair combs and brushes.

Nose: outer skin is greasy and can collect grease, blocking pores.

Armpits and Genital Areas: sweat collects here, encouraging growth of bacteria. Stale sweat smells and can favor growth of pathogens.

Hands: many materials handled are easily spread other parts of the body, particularly the mouth and eyes.

Fingers and toes: sweat between them can soften skin and favor fungal growths.

Nails: dirt etc. under the nails provides food and shelter for many organisms, including parasite eggs.

Feet: bare feet can pick up worm larvae as well as other pathogens from the soil and latrine floor.

Remedial actions

Hair: wash hair, combs and brushes often; at the same time check for head lice and treat if necessary.

Eyes: wash carefully around the eyes, especially of babies, to avoid excess mucus; avoid rubbing, particularly with dirty hands or cloths.

Skin: wash frequently to remove sweat, dirt, dead skin cells and grease. Using soap helps remove this matter and clears pores, essential for skin functions; in the absence of soap, ash can be used.

Hands: wash well, particularly
before preparing food;
before eating;
after excreting;
after gardening;
after handling dirty clothes;
before and after cleaning and treating sores and wounds;
after handling animals and
after handling chemicals at work or in the home.

Nails: keep clean and trim.

Feet: wash dirt and sweat between toes and dry well afterwards to discourage growth of fungi (athlete's foot).

Source: The Worth of Water: Technical Briefs on Health, Water and Sanitation.
with an introduction by John Pickford. Unidentified author, published year, and publisher.

ក្បួនថែរក្សាអនាម័យសំរាប់ស្នប់អណ្តូងជ្រៅ

ការសិក្សា

លើការអភិវឌ្ឍន៍ប្រភពទឹកក្រោមដី

ក្នុងតំបន់ភូមិភាគខាងត្បូងនៃប្រទេសកម្ពុជា



មីនា ១៩៩៩

អ.ធ.ប / ឆៃកា



ការសិក្សាទឹកក្រោមដីភាគខាងត្បូងនៃប្រទេសកម្ពុជា

បញ្ជីអត្ថបទ

គារវកិច្ច

បុព្វកថា

សេចក្តីផ្តើម

✷ ប្រភពទឹកនៅក្នុងប្រទេសកម្ពុជា........ ១

I. ទឹក និងសុភាព........ ២

II. ប្រភេទជំងឺឆ្លងតាមទឹកនៅប្រទេសកម្ពុជា ២

1. ប្រភេទជំងឺឆ្លងតាមការហូបទឹកមិនស្អាត ២

2. ប្រភេទជំងឺឆ្លងតាមបោកគក់ឬមុជទឹកក្រខ្វក់ ៣

3. ជំងឺឆ្លងតាមភ្នាក់ងារចំលង........ ៣

III. ការចូលរួមសហគមន៍និងភារកិច្ចរបស់គណៈកម្មាធិការទឹកត្រូវបានបង្កើត,........ ៣

1. គណៈកម្មាធិការទឹកភូមិ........ ៣

2. គណៈកម្មាធិការអណ្តូងទឹក........ ៣

តារាងរាយប្រភេទជំងឺខ្លះៗ ដែលឆ្លងតាមការប្រើប្រាស់ទឹក ៥-៦

ក្បួនថែរក្សាអនាម័យសំរាប់អណ្តូងស្នប់ជ្រៅ ៧

1. ទឹកស្អាត និងទឹកមិនស្អាត........ ៧

2. ប្រភពទឹក និងការចំលងមេរោគ........ ៧

3. ការការពារអណ្តូងមិនអោយមានមេរោគ ៩

4. របៀបប្រើប្រាស់ទឹកស្អាត ១៣

5. ទឹក និងអនាម័យ ១៥

6. អនាម័យ បរិស្ថានផ្សេងៗទៀតដែលត្រូវលើកយកមកពិចារណា ១៦

រូបភាពតំរង់ទិសសំរាប់អនាម័យផ្ទាល់ខ្លួន ១៨

គារវកិច្ច

សៀវភៅនេះត្រូវបានរៀបចំឡើងដោយមានការខិតខំប្រឹងប្រែងរបស់ក្រុមសិក្សាអភិវឌ្ឍន៍ទឹកក្រោមដី និងក្រុមជំនួយការរបស់អង្គការ ជៃកា បានសហការយ៉ាងជិតស្និទ្ធជាមួយនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទនិងបណ្តាមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ដែលស្ថិតនៅក្រោមកម្មវិធីផ្គត់ផ្គង់ទឹកនេះ។

ទាំងនេះបានញ៉ាំងឱ្យកម្មវិធីសំរេចនូវស្នាដៃរបស់ខ្លួនក្នុងដំណាក់កាលសិក្សាសាកល្បងលើកដំបូង ហើយក៏ជាបទពិសោធន៍ដ៏ល្អដែលអាចឱ្យកម្មវិធីឈានចូលដល់ដំណាក់កាលបន្តបន្ទាប់ទៀតនិងទទួលបានជោគជ័យនូវជំហានក្រោយ ១ ទៀត។ យើងខ្ញុំនឹងពិចារណាថែមទៀតនូវរាល់ការផ្តល់មតិរបស់នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ ។

ជាទីបញ្ចប់នេះយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក ម៉ៅ សារ៉ាយ និង លោក ចាន់ដារ៉ុង ជាប្រធាននិងអនុប្រធាននាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ ដែលបានចូលរួមសំរបសំរួលនិងជួយជ្រោមជ្រែងយ៉ាងខ្លាំងក្លាក្នុងកម្មវិធីនេះ។

យើងខ្ញុំរីករាយនឹងទទួលការកែលំអរពីសំណាក់ ឯកឧត្តម លោក លោកស្រី នូវរាល់ចំនុចខុសឆ្គងដែលមាននៅក្នុងសៀវភៅនេះ។

បុព្វកថា

ក្រុមសិក្សារបស់អង្គការនៃកាបានចាប់ផ្តើមកម្មវិធីអភិវឌ្ឍន៍ទឹកក្រោមដីរបស់ខ្លួនក្នុងតំបន់ភាគខាងត្បូងនៃប្រទេសកម្ពុជាក្នុងលក្ខណៈជាការសិក្សាសាកល្បងចាប់ពីខែធ្នូ ឆ្នាំ1996 ដើម្បីផ្តល់ទឹកស្អាតដល់ខេត្តជាគោលដៅទាំងប្រាំមួយរួមមាន ៖ ជាយក្រុងភ្នំពេញ ស្វាយរៀង ព្រៃវែង តាកែវ កណ្តាល និង កំពង់ស្ពឺ។
ក្នុងពេលដំណើរការនៃកម្មវិធីនេះការសិក្សាសាកល្បងអណ្តូងស្នប់ជ្រៅចំនួន25អណ្តូង ត្រូវបានខួង តំលើងស្នប់ និងចាក់ព្រលានបេតុងរួចបង្កើតឱ្យមាន គណៈកម្មាធិការទឹកភូមិ ការអប់រំសុខភាព អប់រំពីការប្រើប្រាស់ទឹក ហើយការងារ នេះនឹងត្រូវអនុវត្តន៍ជាប់រហូតដល់ឆ្នាំ2002ក្នុងលក្ខណៈអង្កេតជាមូលដ្ឋាន។ សកម្មភាពនៃកម្មវិធីនេះត្រូវបានគេអនុវត្តន៍ឡើងដោយសហការយ៉ាងជិតស្និតជាមួយក្រុមអ្នកត្រួតពិនិត្យនិងសហសេវិករបស់នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ។

ដោយសារព្រឹត្តិការណ៍នយោបាយដែលកើតឡើងកាលពីថ្ងៃទី5 និង ទី6 ខែកក្កដា ឆ្នាំ1997 កម្មវិធីនេះត្រូវផ្អាកបិទជាបណ្តោះអាសន្នអស់រយៈពេល19ខែ។ កម្មវិធីនេះទើបចាប់ផ្តើមសកម្មភាពឡើងវិញនៅថ្ងៃទី17 ខែមិនា ឆ្នាំ1999 ហើយនឹងត្រូវបន្តរហូតដល់ឆ្នាំ2002។ ប្រសិនបើកម្មវិធីសិក្សាសាកល្បងលើកដំបូងទទួលបានជោគជ័យជាវិជ្ជមាននោះ ជំហានបន្ទាប់ក៏អាចចាប់ផ្តើមដំណើរការទៅតាមគំរោងដែលបានស្នើសុំជាអាទិភាពទាំង 300 ភូមិ។ ដោយរួមសហការយ៉ាងជិតស្និតជាមួយនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ យើងបានជ្រើសរើសយកវិធីសាស្រ្តសំរាប់ សហគមន៍អនុវត្តន៍តាមមាន ៖ ការអប់រំអនាម័យ ការប្រើប្រាស់ទឹក និងការបង្កើតគណៈកម្មាធិការទឹកភូមិទាំងអស់នេះគឺក្នុងគោលបំណងផ្សព្វផ្សាយនូវចំណេះដឹងទាំងឡាយដែលពាក់ពន្ធ័ទៅនឹង ទឹកស្អាតនិងអនាម័យ ដល់ប្រជាពលរដ្ឋដែលនៅពុំទាន់យល់ពីផលអាក្រក់បណ្តាលមកពីការប្រើប្រាស់ទឹក ពីប្រភពទឹកមិនស្អាត ដូចជា ត្រពាំង បឹងបួរជាដើម និងដើម្បីកាត់បន្ថយនូវពពួកជំងឺឆ្លងតាមប្រភពទឹកផងដែរ។

ទឹកគឺជាជីវិតបានន័យថា បើទឹកមានលក្ខណៈគ្រប់គ្រាន់ទាំងបរិមាណនិងគុណភាពនោះវាអាចនាំមកនូវផលប្រយោជន៍យ៉ាងសំខាន់ដល់សុខភាព តែផ្ទុយទៅវិញបើទឹកគ្មានលក្ខណៈគ្រប់គ្រាន់ទាំងបរិមាណនិងគុណភាពហើយព្រមទាំងគ្មានអនាម័យផងនោះ បណ្តាជំងឺឆ្លងតាមទឹកផ្សេងៗនឹងអាចកើតមានឡើងដូចជា រាគមួលនិងគ្រុនពោះវៀនជាដើម។

ដូច្នេះសំខាន់បំផុតនោះគឺការបង្កើនគុណភាពប្រភពទឹកក៏ដូចជាសំណង់អនាម័យ ដែលជាមធ្យោបាយមួយអាចកាត់បន្ថយការកើតមានឡើងនូវជំងឺទាំងឡាយឬក៏អាចបំបាត់ទាំងស្រុង ។ហើយក៏រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក៏អាចផ្លាស់ប្តូរវិវឌ្ឍន៏រីកចំរើនទៅមុខដែរ ។

តាមរយៈការដកពិសោធន៏ក្នុងផ្នែកផ្គត់ផ្គង់ទឹកតាមជនបទដែលដកស្រង់ចេញពីឯកសារខ្លះៗរបស់អង្គការក្រៅរដ្ឋាភិបាលនិងការអនុវត្តន៏ជាក់ស្តែងរបស់អង្គការផែកាលើការអប់រំអនាម័យនិងការប្រើប្រាស់ទឹក បានធ្វើឱ្យកម្មវិធីនេះទទួលបាននូវលទ្ធផលយ៉ាងគាប់ប្រសើរ ។

ដូច្នេះយើងផ្តោតអារម្មណ៏សង្កត់ធ្ងន់លើបញ្ហាសំខាន់ៗនៃសកម្មភាពដែលអនុវត្តន៏ ដើម្បីធ្វើឱ្យប្រជាពលរដ្ឋបានយល់ច្បាស់ពីសារៈប្រយោជន៏សំខាន់នៃ ទឹកនិងអនាម័យ ហើយអាចផ្លាស់ប្តូរនូវទំលាប់មិនសមស្របចោល ។

សេចក្តីផ្តើម

នៅឆ្នាំ 1993 នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទបានធ្វើសេចក្តីស្នើសុំ កម្មវិធីផ្គត់ផ្គង់ទឹក ពីរដ្ឋាភិបាលប្រទេសជប៉ុន សំរាប់500ភូមិ នៅភាគខាងត្បូងនៃប្រទេសកម្ពុជាតាមរយៈអង្គការនៃការភ្នំពេញ ហើយអង្គការនេះបានបង្កើត ក្រុមសិក្សាដំណើរការកម្មវិធីអភិវឌ្ឍន៍ទឹកក្រោមដីនៅ ខែធ្នូ ឆ្នាំ1996 ដើម្បីឆ្លើយតបតាម សំណើរសំរាប់ផ្គត់ផ្គង់ទឹកក្នុងខេត្តទាំង6។

ក្នុងកំឡុងនៃកម្មវិធីផ្តល់ទឹកស្អាតតាមជនបទនេះអង្គការនៃការបានបង្កើតជាយុទ្ធសាស្ត្រឆ្លើយតបនិងជួយកាត់បន្ថយនូវជំងឺទាំងឡាយតាមរយៈនៃការប្រើប្រាស់ទឹកក្រខ្វក់ដោយដាក់បញ្ចូលនូវ ការអប់រំទឹកនឹងអនាម័យគឺចង់លើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រ ។

ទំហំ (Scope)

ឯកសារនេះពិពណ៌នានូវដំណើរការនៃកម្មវិធីផ្គត់ផ្គង់ទឹកស្អាត ការអប់រំទឹកនិងអនាម័យ ដើម្បីបង្កើតឱ្យមានការជឿជាក់លើផលប្រយោជន៍នៃការផ្តល់ទឹកស្អាតសំរាប់បរិភោគ។ ដំណើរការនេះមានបញ្ចូលទាំងការអប់រំសង្គមសំរាប់ ការរួបរួមសហគមន៍ព្រមទាំងអប់រំផ្នែកបច្ចេកទេសដល់គណៈកម្មការសំរាប់ប្រតិបត្តិការថែទាំនឹងជួសជុលស្នប់អណ្តូង។

✱ <u>ប្រភពទឹកនៅក្នុងប្រទេសកម្ពុជា</u>

នៅក្នុងប្រទេសកម្ពុជា ជាទូទៅប្រជាពលរដ្ឋពឹងពាក់ទឹកលើដីដូចជា ទឹកស្រះ(ស្រះឯកជននិងស្រះសាធារណៈ) ប្រលាយ ស្ទឹង អូរ ទន្លេ ព្រែក ត្រពាំង អណ្តូងរាក់ និងទឹកភ្លៀង។ ទឹកភ្លៀងគឺជាទឹកដែលគេចូលចិត្តផឹកបំផុត(តាមការស្ទង់មតិ) គឺរដូវវស្សាចាប់ផ្តើមពី ខែឧសភា ដល់វិច្ឆិការ។ នៅពេលរដូវប្រាំងមកដល់ស្រះជាច្រើននិងប្រភពទឹកផ្សេងៗទៀតរីងស្ងួតអស់បណ្តាលឱ្យមានការខ្វះខាតទឹកសំរាប់ប្រើប្រាស់។ ដូច្នេះប្រជាពលរដ្ឋនៅទីនោះត្រូវទៅដងទឹកពីទីឆ្ងាយ ដែលជាប្រភពទឹកមានលក្ខណៈខ្វះនាម័យដើម្បីយកមកប្រើប្រាស់។ ហើយពេលនោះគេចាប់ផ្តើម រំពឹងលើអណ្តូងស្នប់ ឬ រកទិញទឹក។

តាមការពិសោធន៍និងពិនិត្យអង្កេតលើគុណភាពទឹកប្រើប្រាស់បង្ហាញឱ្យឃើញថាប្រភពទឹកភាគច្រើនបំផុតដែលប្រជាពលរដ្ឋតែងតែប្រើគឺជាទឹកមិនស្អាត (ទឹកត្រពាំង ស្ទឹង បឹង ទន្លេ ប្រឡាយ ស្រះ អូរ) គេប្រើសំរាប់សេចក្តីត្រូវការផ្សេងៗគ្នា អ្នកខ្លះសំរាប់លាងសត្វពាហនៈ អ្នកខ្លះសំរាប់បោកគក់សំលៀក បំពាក់ ខ្លះមុជ --។ល។

ចំណែកអណ្តូងលូវិញគេកម្រធ្វើប្រពន្ធ័ការពារណាស់ដូចជាគ្មានគំរបគ្មានប្រដាប់យោងទឹកឡើង ។ហើយអ្នកភូមិទាំងនោះតែងតែយោងទឹកពីអណ្តូងដោយប្រើធុងទឹកផ្ទាល់របស់គេម្នាក់ៗដែលនាំឱ្យអណ្តូងទឹកនោះក្រខ្វក់ ។

I. ទឹក និងសុខភាព

ក្នុងចំណោមជំងឺសំខាន់ៗជាច្រើនប្រភេទដែលមានក្នុងប្រទេសកំពុងអភិវឌ្ឍន៍នោះមានជំងឺមួយចំនួនដែលទាក់ទងទៅនឹងបញ្ហាប្រើប្រាស់ទឹកនឹងអនាម័យ ដែលក្នុងនោះក៏មានជំងឺប្រហែលជា10ប្រភេទទៀតក្នុងចំណោមជំងឺទាំងនោះដែលត្រូវបានគេលើកយកមកពិចារណាជាដំបូងបង្អស់ (ជំងឺរាគរូស ជំងឺគ្រុនពោះវៀន ជំងឺថ្លើម អាម៉ិប ព្រូនជាដើម) ។ ជំងឺប្រភេទទាំងនេះគឺជាមូលដ្ឋានដែលអាចបង្ករឱ្យមានជំងឺផ្សេងៗជាច្រើនអតិប្បរមារៀងរាល់ឆ្នាំ ហើយជំងឺ ដែលជាមច្ចុរាជនិងគ្រោះថ្នាក់បំផុតនោះគឺជំងឺរាគរូស ។

វាជាការសំខាន់ណាស់ដែលយើងត្រូវយល់ដឹងឱ្យបានច្រើនតាមរយៈការសិក្សា និងស្រាវជ្រាវអំពីប្រភេទជំងឺឆ្លង ទាំងឡាយដែលទាក់ទងនិងការប្រើប្រាស់ទឹក ។ ការផ្គត់ផ្គង់ទឹក និង អនាម័យគួរតែយកចិត្តទុកដាក់លើបញ្ហាសុខភាព មិនមែនលើបញ្ហាប្រភេទជំងឺទេ ។ ទឹកនឹងអនាម័យ និងការអប់រំអនាម័យ ជាគោលដៅសំរាប់ការពារនិងថែរក្សាមនុស្សឱ្យមានសុខភាពល្អ ។ ចុងក្រោយបំផុតការងារទាំងនេះមិនត្រឹមតែបានជួយឱ្យកុមារទាំងឡាយអាចរួចរស់ជីវិតពីជំងឺនានានោះទេ ថែមទាំងជួយធ្វើឱ្យកុមារទាំងឡាយទៅសាលារៀននិងទទួលផលប្រយោជន៍ពេញលេញពីការអប់រំ ដោយមិនមានកើតព្រូន មិនខាតបង់ពេលវេលាដោយសារជំងឺជ្រាកុងកុឡា ឬជំងឺគ្រុនចាញ់ និងមិនមានការឈឺចាប់ក្នុងរយៈ ពេលកើតជំងឺរាករាំរ៉ៃ ។

II. ប្រភេទជំងឺឆ្លងតាមទឹកនៅប្រទេសកម្ពុជា

តាមការសិក្សាស្រាវជ្រាវកន្លងមករបស់អង្គការផែនការនិងទិន្នន័យឯកសារខ្លះៗ របស់អង្គការក្រៅរដ្ឋាភិបាលក៏ដូចជាអង្គការរដ្ឋាភិបាលផងដែរ ដែលបានជួបប្រទះនៅបញ្ហាប្រភេទជំងឺឆ្លងតាមរយៈការប្រើប្រាស់ទឹកមិនស្អាត ការខ្វះខាតខាងផ្នែកអប់រំសុខភាពនិងអនាម័យនៅតាមជនបទនានា ។ ហេតុផលទាំងនេះបានបង្កើតឱ្យមានកម្មវិធីផ្គត់ផ្គង់ទឹកស្អាតនិងការអប់រំសុខភាព អនាម័យតាមសហគមន៍នានា ដែលពុំទាន់ទទួលយល់ដឹងនៅឡើយអំពី បញ្ហាទាំង នេះ ។

ប្រភេទជំងឺដែលតែងតែជួបប្រទះសព្វថ្ងៃនេះ ភាគច្រើនកើតឡើងតាមការប្រើប្រាស់ និងបរិភោគទឹកមិនស្អាត ដែលនឹងរៀបរាប់ដូចខាងក្រោម :

1- ប្រភេទជំងឺឆ្លងតាមការហូបទឹកមិនស្អាត

ប្រភេទជំងឺបែបនេះត្រូវបានឆ្លងមកមនុស្សតាមរយៈការប្រើប្រាស់ទឹកមិនស្អាត សំរាប់បរិភោគដោយមិនបានចំអិនជាមុនមានដូចជា : ជំងឺរាគរូស អាសន្នរោគ គ្រុនពោះវៀន ជំងឺថ្លើម A, E ពពួកព្រូនផ្សេងៗ ដែលតែងតែ

ជួបប្រទះក្នុងជីវភាពរស់នៅតាមជនបទសព្វថ្ងៃ។

2- **ប្រភេទជំងឺឆ្លងតាមការបោកគក់ឬមុជទឹកគ្រោះថ្នាក់**

ការប្រើប្រាស់ទឹកមិនស្អាត តាមការបោកគក់ និងមុជទឹកក៏អាចជះឥទ្ធិពលមកលើសុខភាពរបស់មនុស្សយើងបានដែរ។ប្រភេទជំងឺនេះមានដូចជា : ជំងឺសើរស្បែក កមរមាស់ សន្ទះឱម៉ាល់ ។

3- **ជំងឺឆ្លងតាមភ្នាក់ងារចំលង**

ប្រភេទជំងឺនេះអាចឆ្លងតាមរយៈមូសខាំ ដែលអាចបណ្តាលឱ្យមានជំងឺគ្រុនចាញ់ គ្រុនឈាមជាដើម។ ដើម្បីជៀសវាងនូវប្រភេទជំងឺទាំងនេះបានទាំងស្រុង គួរតែអនុវត្តន៍ទៅតាមក្បួនអនាម័យដូចដែលមានទៅតាមការអប់រំសុខភាពអនាម័យរបស់ក្រសួងសុខាភិបាល និងអង្គការក្រៅរដ្ឋាភិបាលនានាដែលបានផ្សព្វផ្សាយតាមរយៈ វិទ្យុ ទូរទស្សន៍ ខិតប័ណ្ណ តាមរូបភាពដែលទាក់ទងទៅ និងការអប់រំសុខភាពនឹងអនាម័យផ្សេងៗ ទៀត។

III. ការចូលរួមសហគមន៍និងភារកិច្ចរបស់គណៈកម្មាធិការទឹកស្អាតបានបង្កើត

កម្មវិធីផ្គត់ផ្គង់ទឹកសាកល្បងរបស់អង្គការ ឆៃកាក្នុងបណ្តាខេត្តទាំង6 ត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាទៅលើវិស័យអប់រំសុខភាព អនាម័យក្រៅប្រព័ន្ធ និងការខិតខំចងក្រងក្បួនច្បាប់ទាំងនេះ បន្ទាប់ពីបានផ្តល់អណ្តូងស្នប់ដល់សហគមន៍។

ដោយមានការសហការយ៉ាងជិតស្និត ជាមួយនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទបានឯកភាពគ្នាលើចំនុច ការបង្កើតគណៈកម្មាធិការទឹកភូមិ និងគណៈកម្មាធិការថែរក្សាជួសជុលអណ្តូងស្នប់ថ្នាក់ភូមិ កម្មវិធីបង្រៀនគណៈកម្មាធិការទាំងនេះឱ្យចេះជួសជុលថែរក្សា និងយល់ដឹងអំពីសុខភាពសង្គម អនាម័យការប្រើប្រាស់ និងអនាម័យទូទៅដើម្បីឱ្យគេផ្សព្វផ្សាយការយល់ដឹងទាំងនេះទៅអ្នកប្រើប្រាស់។

សហគមន៍ទាំងអស់ត្រូវមាន :

1- គណៈកម្មាធិការទឹកភូមិមានសមាជិក :

- ប្រធាន : ទទួលខុសត្រូវរួម
- លេខាធិការ : ទទួលខុសត្រូវផ្នែកកំណត់ហេតុផ្សេងៗ
- បេឡាធិការ : ទទួលខុសត្រូវផ្នែកប្រមូលថវិការពីសហគមន៍

2- គណៈកម្មាធិការអណ្តូងទឹក មានសមាជិក :

- អ្នកជួសជុល 2នាក់ មានភារកិច្ចជួសជុលទាំងការខូចស្នប់តូចតាចទាំងខឿនអណ្តូង កាលណាវាបែកបាក់ ។

- អ្នកថែរក្សា 2នាក់ មានភារកិច្ចថែរក្សាអនាម័យលើអណ្តូងទាំងក្នុងសហគមន៍ និងជួយផ្សព្វផ្សាយផ្នែកអប់រំសុខភាព និង អនាម័យដល់អ្នកប្រើប្រាស់តាមរយៈកម្មវិធីរបស់អង្គការឆៃកា(JICA)និង ក្រសួងអភិវឌ្ឍន៏

ជនបទ ទាំងគណៈកម្មាធិការទឹកភូមិ និងគណៈកម្មាធិការអណ្តូងទឹកត្រូវបានអង្គការឆែកានិងក្រសួងអភិវឌ្ឍន៍ជនបទ ផ្តល់នូវ សំភារៈ* ស្មារតី និងការបង្រៀនក្បួនជួសជុលថែរក្សាអណ្តូងស្នប់សំរាប់រយៈពេលយូរ និងការអប់រំអនាម័យ ក្នុងរយៈពេល ៣ ថ្ងៃចំពោះសហគមន៍នីមួយៗ ក្នុងភូមិ ។

សំភារៈ:* (មានក្បួនបង្កើតគណៈកម្មាធិការទឹកភូមិ និងគណៈកម្មាធិការអណ្តូងទឹក ក្បួនជួសជុល និងថែរក្សាស្នប់ ក្បួនថែរក្សាអនាម័យ ចំពោះស្នប់ដៃ ផ្ទាំងរូបភាព និងខិតបណ្ណ័អំពីអនាម័យប្រើប្រាស់ទឹក សំភារៈប្រើប្រាស់ដែលទាក់ទងសុខភាព និងសំភារៈសំរាប់ជួសជុល) ។

តារាងរាយប្រភេទជំងឺខ្លះៗដែលឆ្លងតាមការប្រើប្រាស់ទឹក

ឈ្មោះជំងឺ	វិធីចំលង	វិធីបង្ការ	រោគសញ្ញា
- រាគរូស	- ឆ្លងតាមការបរិភោគទឹកមិនស្អាត - ឆ្លងតាមរយៈចំណីអាហារ - ប្រើប្រាស់សំភារៈអ្នកជំងឺដែលមិនស្អាត	- ត្រូវបរិភោគទឹកស្អាតឬ ដាំឱ្យពុះ - ចំណីអាហារត្រូវគ្របឱ្យជិត ជៀសវាង រុយរោម និងចំអិនឱ្យបានឆ្អិនល្អ - មិនត្រូវប្រើសំភារៈអ្នកជំងឺដោយមិន សំអាតនោះទេ	- លាមករាវលើសពី៣ដងក្នុងមួយថ្ងៃ , គ្មានក្អួត , ភ្នែករូង បបូរមាត់ស្ងួត ស្រេកទឹក , គ្មានទឹកនោម , បង្ហើយផត , ស្បែកជ្រួញ ។
- អាសន្នរោគ	- ឆ្លងតាមការបរិភោគទឹកមិនស្អាត - ឆ្លងតាមរយៈចំណីអាហារ - ប្រើប្រាស់សំភារៈអ្នកជំងឺដែលមិនស្អាត	- ត្រូវបរិភោគទឹកស្អាតឬ ដាំឱ្យពុះ - ចំណីអាហារត្រូវគ្របឱ្យជិត ជៀសវាង រុយរោម និងចំអិនឱ្យបានឆ្អិនល្អ - មិនត្រូវប្រើសំភារៈអ្នកជំងឺដោយមិនសំអាតនោះទេ	-រាគខ្លាំងសុទ្ធតែទឹក លាយជាមួយគ្រាប់ពណ៌សដូចចុងអង្ករ លាមកមានក្លិនឆ្អាប , កំអួតមានលក្ខណៈដូចលាមក ក្អួតមិនបាច់ប្រឹង មានរមួលក្រពើ ភ្នែករូងហើយបញ្ឈរប្រស្រី ជិបចរញ្ជាប់ គ្មានទឹកនោម ។
- គ្រុនពោះវៀន	- ឆ្លងតាមការបរិភោគទឹកមិនស្អាត - ឆ្លងតាមរយៈចំណីអាហារ - ប្រើប្រាស់សំភារៈអ្នកជំងឺដែលមិនស្អាត	- ត្រូវបរិភោគទឹកស្អាតឬ ដាំឱ្យពុះ - ចំណីអាហារត្រូវគ្របឱ្យជិត ជៀសវាង រុយរោម និងចំអិនឱ្យបានឆ្អិនល្អ - មិនត្រូវប្រើសំភារៈអ្នកជំងឺដោយមិនសំអាតនោះទេ	- ចុកឆ្អិលឆ្អល់ , រាករូស ឬ ទល់លាមកអ្នកជំងឺអស់កំលាំង ឈឺក្បាលជាប់ជានិច្ច , រូមិតខ្លួន , ដេកមិនលក់ , យល់សប្តិច្រើន , មិនឃ្លានបាយ , អណ្តាតស ។
- ជំងឺថ្លើមប្រភេទ A, E	- ឆ្លងតាមការបរិភោគទឹកមិនស្អាត - ឆ្លងតាមរយៈចំណីអាហារ - ប្រើប្រាស់សំភារៈអ្នកជំងឺ ដែលមិនស្អាត	- ត្រូវបរិភោគទឹកស្អាតឬ ដាំឱ្យពុះ - ចំណីអាហារត្រូវគ្របឱ្យជិត ជៀសវាង រុយរោម និងចំអិនឱ្យបានឆ្អិនល្អ - មិនត្រូវប្រើសំភារៈអ្នកជំងឺដោយមិនសំអាតនោះទេ	- ស្បែក និង ភ្នែកពណ៌លឿង , ទឹកនោមឡើងលឿងចាស់ , លាមកស បន្តិចម្តងៗ ។

ឈ្មោះជំងឺ	វិធីចំលង	វិធីបង្ការ	រោគសញ្ញា
- រាគមូល	- ឆ្លងតាមការបរិភោគទឹកមិនស្អាត - ឆ្លងតាមរយៈចំណីអាហារ - ប្រើប្រាស់សំភារៈអ្នកជំងឺដែលមិនស្អាត	- ត្រូវបរិភោគទឹកស្អាតឬ ដាំឱ្យពុះ - ចំណីអាហារត្រូវគ្របឱ្យជិត ជៀសវាង រុយរោម និង ចំអិនឱ្យបានឆ្អិនល្អ - មិនត្រូវប្រើសំភារៈអ្នកជំងឺដោយមិនសំអាតនោះទេ	- អ្នកជំងឺឈឺជុះញាប់ ប៉ុន្តែគ្មានលាមក ឬ មានតិចតួច ដោយលាយ សំបោរ ឬ លាយឈាម ។ លាមកមិនធុំក្លិនស្អុយទេ តែឆ្អាប ស្ថានភាពទូទៅរបស់អ្នកជំងឺចុះខ្សោយ ។ - អ្នកជំងឺក្តៅខ្លួន ប្រសិនបើការរាគមូលបណ្តាលមកពីមេរោគបាស៊ី ។ តែមិនក្តៅខ្លួនប្រសិនបើបណ្តាលមកពីពពួកអាម៉ីម ។
- គ្រុនស្វិតដៃជើង	- ឆ្លងតាមការបរិភោគទឹកមិនស្អាត - ចំណីអាហារដែលមានមេរោគ - លាមកអ្នកជំងឺ ឬ លាមកអ្នកមានមេរោគ តែគ្មានសំដែងនូវលក្ខណៈជំងឺ	- បរិភោគទឹកដាំពុះ - ត្រូវប្រើបង្គន់អនាម័យ បើគ្មានត្រូវកប់ឱ្យជ្រៅ - អនាម័យខ្លួនប្រាណ	- អ្នកជំងឺច្រើនតែសម្ងំស្ងៀម - គ្រុនផ្តាសាយ តែម្យ៉ាង ឬ មានឡូកឡំ និង វិបត្តិរំលាយអាហារ , រាគស្រួចស្រាវ , រលាកស្រោមខួរ ដោយទឹកខួរឆ្អឹងខ្នងថ្លា
- ជំងឺសើរស្បែក កមរមាស់	- ឆ្លងតាមការបោកគក់ ឬ មុជទឹកមិនស្អាត	- ត្រូវមុជទឹកស្អាតដែលមានប្រពន្ធ័ត្រឹមត្រូវ - ត្រូវសំអាតសំលៀកបំពាក់ និង ប្រដាប់ប្រដារប្រើប្រាស់រាល់ថ្ងៃ	- រមាស់នៅពេលយប់, ទិដ្ឋភាពរលាកស្បែក មានខ្ទុះតាមកន្លែងឧស្សាហ៍រមាស់ជាងគេ គឺ កេរ្តិ៍ភេទ (ក្លៀក , គល្បៀន , ពោះ , ដោះ , កដៃ , ភ្លៅសង្វារ
- ជំងឺសន្ទុះឱម៉ាល់	- ចំលងតាមការមុជទឹក បោកគក់ និង ការប្រើប្រាស់ប្រភពទឹកមិនស្អាត	- ប្រើទឹកអណ្តូងស្នប់ដើម្បីងូត ចំពោះទឹកទន្លេត្រូវស្តុកទុកឱ្យបានលើស 12 ម៉ោង - បង្គន់អនាម័យ ឬ ជីកកប់	- រាគរូសឈាម និង សំបោរ - ការលូតលាស់យឺតហើយស្គម ចំពោះក្មេងអាចស្លាប់បណ្តាលមកពីក្អួតឈាម

ក្បួនថែរក្សាអនាម័យសំរាប់ស្នប់អណ្តូងជ្រៅ

១. ទឹកស្អាត និង ទឹកមិនស្អាត

ទឹកស្អាតមានអនាម័យសំរាប់បរិភោគ គឺជាទឹកដែលមិនបង្កឱ្យមានជំងឺ។ ទឹកក្រខ្វក់គឺជាទឹកបង្កឱ្យមានជំងឺ។ ឧទាហរណ៍ បើបរិភោគទឹកមានមេរោគវាអាចបង្កឱ្យមានជំងឺឆ្លងតាមទឹកដូចជា រាគរូស មួល និង គ្រុនពោះវៀនជាដើម។ ហើយម្យ៉ាងទៀតបើទឹកប្រើប្រាស់ប្រចាំគ្រួសារក្រខ្វក់ ខ្វះអានាម័យនោះក៏បណ្តាល ឱ្យកើតជំងឺសើស្បែក និង ឆ្លងដែរ ដូចជា កមរមាស់ និង ត្រាក់កូមជាដើម ។

ជាទូទៅមនុស្សពេញវ័យមានភាពទប់ទល់នឹងជំងឺទាំងនេះ។ ប៉ុន្តែចំពោះកូនក្មេងវិញ វាងាយកើតជំងឺនេះ ណាស់ តែបើកាលណាប្រជាជនប្រើប្រាស់ទឹកស្អាតនោះ ជំងឺទាំងនេះក៏អាចការពារបានដែរ។ ក្រសួង អភិវឌ្ឍន៍ជនបទ (អជប)និងអង្គការឆៃកា បានជីកអណ្តូងរួចតំលើងស្នប់និងចាក់ព្រលានបេតុង។ ដូច្នេះប្រជាជនអ្នកភូមិអាច មានលទ្ធភាព ប្រើប្រាស់ទឹកស្អាត ។

២. ប្រភពទឹក និង ការចំលងមេរោគ

មានប្រភពទឹកប្លែកៗ គ្នាច្រើនប្រភេទនៅក្នុងភូមិនីមួយៗ ដូចជា ទឹកភ្លៀង ទន្លេ ស្ទឹង ប្រលាយ បឹង ត្រពាំង អណ្តូងលូ អណ្តូងខួងជាដើម។ ប្រភពទឹកទាំងនេះអាចចំលងមេរោគបានដូចគ្នា វាគ្រាន់តែកំរិតនៃការចំលង នោះខុសគ្នាតែប៉ុណ្ណោះ ។

ទឹកភ្លៀងពិបាកចំលងមេរោគណាស់លើកលែងតែនៅតំបន់ណាដែលមានរោងចក្រ។ ទឹកត្រពាំងមានភាពងាយ ស្រួលក្នុងការចំលងមេរោគណាស់ពីព្រោះគោក្របីឬជ្រូក អាចចុះលេងទឹកក្នុងទីនោះបាន។ ទឹកបឹងក៏មានភាព ដូចគ្នានិងទឹកត្រពាំងដែរ គ្រាន់តែល្បឿននៃភាពចំលងយឺតជាងពីព្រោះបឹងមានទំហំ ធំជាងត្រពាំង។ ចំពោះទឹក ប្រលាយ ស្ទឹង ទន្លេវិញ មិនសូវចំលងមេរោគប៉ុន្មានទេព្រោះទឹកហូរ ។

មូលហេតុដែលធ្វើអោយទឹកកខ្វក់



ត្រូវធ្វើរបងដើម្បីការពារសត្វពាហនៈ



ប្រសិនបើមនុស្សឬសត្វបន្ទោរបង់ដាក់ពីលើខ្សែទឹក នោះទឹកនឹងទទួលភាពកខ្វក់តាមបណ្តោយខ្សែទឹករហូតមកដល់ក្រោម។ ចំពោះអណ្តូងលូនិងអណ្តូងខួងវិញ ងាយទទួលមេរោគតាមការជ្រាបចូលរបស់ទឹកមិនស្អាតនៅក្បែរអណ្តូង។ ទោះជាយ៉ាងណាក៏ដោយអណ្តូងខួងគឺជាអណ្តូងមានដាក់បំពងនិងស្នប់។ ឯអណ្តូងលូវិញគឺជាអណ្តូងចំហរហើយរាក់ជាងអណ្តូងខួង ដូច្នេះមេរោគអាចជ្រាបចូលបានងាយជាង ។
ហេតុដូចនេះហើយបានជាក្រសួងអភិវឌ្ឍន៍ជនបទនិងអង្គការផែកា ខិតខំខួងអណ្តូងជ្រៅពីព្រោះអណ្តូងទាំងនេះជ្រៅជាងអណ្តូងដែលខួងដោយអង្គការនានា ដូច្នេះមេរោគមិនអាចជ្រាបចូលបានដោយងាយទេ។ តែទោះជាយ៉ាងនេះក៏ដោយ ក៏មេរោគគង់អាចជ្រាបចូលបានលើកលែងតែអ្នកប្រើប្រាស់ បានអនុវត្តន៍តាមវិធានការណ៍ការពារ។ ដើម្បីការពារអ្នកប្រើប្រាស់ត្រូវសំអាតភាពក្រខ្វក់ និង អ្វី១ទាំងពួងដែលបង្កឱ្យមានមេរោគចេញពីបរិវេណជុំវិញអណ្តូង ។

៣. ការការពារអណ្តូងមិនឱ្យមានមេរោគ

ដើម្បីថែរក្សាទឹកឱ្យបានស្អាត អ្នកភូមិត្រូវតែរក្សាការពារស្នប់អណ្តូងខឿនអណ្តូងទីធ្លាជុំវិញអណ្តូងឱ្យបានស្អាតជានិច្ច ។

- ស្នប់អណ្តូង ខឿនអណ្តូង និង ទីធ្លាជុំវិញអណ្តូងត្រូវរក្សាឱ្យស្អាតជានិច្ច ។
- មិនត្រូវហាលសំពត់ខោអាវលើស្នប់អណ្តូង ។
- មិនត្រូវចោលសំរាមលើខឿនអណ្តូង ឬ ទីធ្លាជុំវិញនោះទេ ។
- មិនត្រូវដះទឹកក្រខ្វក់នៅលើទីធ្លាជុំវិញខឿនអណ្តូងទេ ។
- ប្រសិនបើមានគ្រលុកទឹកដក់ នៅលើទីធ្លាជុំវិញស្នប់អណ្តូង ត្រូវស្តារទឹកក្រខ្វក់នោះចេញ រួចលុបដីបំពេញគ្រលុកទាំងនោះ ។
- ត្រូវធ្វើរបងការពារសត្វពាហនៈឱ្យនៅឆ្ងាយពីអណ្តូង និង ខឿនអណ្តូង ។
- មិនត្រូវធ្វើកន្លែងចោលសំរាម ឬ បង្គន់នៅក្បែរអណ្តូង ស្នប់។
- មិនត្រូវឱ្យចង្អូរបង្ហូរទឹកកាកសំណល់ស្ទះ ។
- ក្នុងករណីបើចង្អូរទឹកស្ទះត្រូវសំអាតវាចេញ
- មិនត្រូវបោកគក់ ឬ ងូតទឹកនៅលើខឿនអណ្តូងទេ ។

កុំហាលសំពត់អាវនៅលើស្នប់អណ្តូង
រក្សាភាពស្អាតនៅលើខឿនអណ្តូងជានិច្ច
កុំចាក់ទឹកកខ្វក់ចោលក្បែរជុំវិញខឿនអណ្តូង



ការពារយ៉ាងណាឱ្យសត្វពាហនៈនៅឆ្ងាយពីស្នប់និងខឿនអណ្តូង
ហាមចោលសំរាមឬធ្វើបង្គន់នៅក្បែរអណ្តូង



មិនត្រូវងូតទឹកលើខឿនឬក្បែរខឿនអណ្ដូង



មិនត្រូវបោកគក់លើខឿនអណ្ដូង



លាងសំអាតធុងវែកទឹក



ប្រើប្រាស់ធុងវែកទឹកមានគំរប
ហើយគ្របវានៅពេលវែកទឹក

លាងសំអាតពាងឱ្យបាន
ល្អិតល្អាប់



គ្របគំរបពាងទឹក ដូច្នេះ
ធូលីសំរាមមិនអាចហុយចូលបាន



ត្រូវប្រើចោយមានដងវែងសំរាប់ដងទឹកពីពាង



៤. របៀបប្រើប្រាស់ទឹកស្អាត

ប្រសិនបើប្រជាជនចង់យកទឹកស្អាតពីអណ្តូងមកប្រើប្រាស់ គេគប្បីប្រុងប្រយ័ត្នក្នុងការទុកដាក់ទឹកនោះឱ្យបានល្អត្រឹមត្រូវ សូម្បីជាទឹកនោះស្អាតយ៉ាងណាក៏ដោយ ។ ប្រសិនបើវាទទួលភាពក្រខ្វក់ហើយវានឹងក្លាយជាទឹកមិនស្អាតហើយវាមិនអាចក្លាយមកជាទឹកស្អាតបានវិញទេបើមិនចំអិនវា ។ ដូច្នេះការប្រុងប្រយ័ត្នត្រូវតែអនុវត្តន៍ដូចខាងក្រោម :

ក. ពេលត្រងទឹក

- ដុសលាងសំអាតធុងរែកទឹក ឬ ធុងដឹកជញ្ជូនទឹក (ដោយប្រើសាប៊ូរាវឬផេះ)
- ពិនិត្យមើលចំពួយស្នប់អណ្តូង ក្រែងក្រខ្វក់ បើដូច្នោះត្រូវដុសលាងវា ។

ខ. ពេលរែក ឬ ដឹកជញ្ជូនទឹក

- ត្រូវការពារក្រែងមានធូលីសំរាមហុយចូលក្នុងទឹក ។
- បើអាចធ្វើបានធុងទឹកត្រូវមានគំរប ហើយប្រាកដថាវាគ្របរួចហើយ នៅពេលជញ្ជូនទឹក ។

គ. ការស្តុកទឹក

- ដុសលាងសំអាតពាងឱ្យបានញឹកញាប់ (ដោយប្រើសាប៊ូរាវ ឬ ផេះ)
- ការពារកុំឱ្យធូលី សំរាម ហុយចូលក្នុងពាង នៅពេលយើងចាក់ទឹកចូលទៅក្នុងពាង ។
- ពេលស្តុកទឹកចូលក្នុងពាងត្រូវប្រាកដថាគំរបគ្របបានត្រឹមត្រូវ ដើម្បីការពារកុំឱ្យសំរាមធូលីហុយចូលបាន ។

ឃ. ការប្រើប្រាស់ទឹក

- ត្រូវប្រើបោយមានដងវែង សំរាប់ដួសទឹកចេញពីពាង ។
- ត្រូវដុសលាងបោយ រាល់ពេលមុនយកវាទៅដួសទឹកក្នុងពាង ។
- មិនត្រូវបរិភោគទឹកក្នុងបោយផ្ទាល់មាត់ទេ ។
- មិនត្រូវប្រើអ្វីផ្សេងទៀត ជ្រលក់ទឹកក្នុងពាងក្រៅពីបោយ (ដូចជាដៃ, ពែង ឬ ផ្តិល)

ង. ការចំអិនទឹក

ពេលណាគ្មានទឹកស្អាតសំរាប់ប្រើប្រាស់គ្រប់គ្រាន់ទេ ទឹកមិនស្អាតក៏អាចប្រើប្រាស់បានដែរ បើយើងបានចំអិនវាសំលាប់មេរោគ ដែលជាមូលហេតុសំខាន់បង្កជំងឺ ។

មុនពេលបរិភោគទឹកដែលយើងមិនដឹងថាវាជាទឹកស្អាតឬមិនស្អាតនោះ យើងត្រូវចំអិនវាជាមុនសិនទើបប្រសើរ

ច. <u>ការច្រោះទឹក</u>

ទឹកល្អក់ឬទឹកមានជាតិដែកច្រើនអាចធ្វើការចំរោះបាន។ ក្រសួងអភិវឌ្ឍន៍ជនបទនិងអង្គការផែកា បានសាងសង់អាងច្រោះទឹកអណ្តូងនៅក្នុងភូមិ។ អាងច្រោះនេះវាអាចច្រោះជាតិមិនល្អខ្លះបានដូចជាជាតិ ដែកចេញពីទឹក នៅពេលវាហូតឆ្លងកាត់តំរងក្រណាត់ខ្សាច់ និងគ្រួស ។

សូមធ្វើការប្រុងប្រយត្ន័ចំពោះអាងច្រោះទឹក តាមសេចក្តីណែនាំដូចខាងក្រោម :

- ស្នឹមកំណរជាតិដែកកាន់ជាប់បន្តិចម្តងៗ ទៅនឹងតំរងក្រណាត់គ្រួសនិងខ្សាច់នៅក្នុងអាងចំរោះ។ ដូច្នេះតំរងក្រណាត់គ្រួសនិងខ្សាច់ត្រូវដុសលាងសំអាតរាល់៣ខែម្តងឬ ត្រូវដូរថ្មីប្រសិនបើចាំបាច់ក្នុងពេលនោះត្រូវបង់គួរចូលក្នុងអាងចំរោះផង ។

- ត្រូវប្រាកដថាគ្មានធូលី សំរាមធ្លាក់ចូលក្នុងអាងចំរោះ ។

- ត្រូវរក្សាបរិវេណជុំវិញរូប៊ីណេទឹកឱ្យស្អាតជានិច្ច ។

- កុំជះទឹកចោលនៅក្នុងបរិវេណជុំវិញខឿនស៊ីម៉ង់ (សូមយកក្បួនប្រើប្រាស់ និង ជួសជុលស្នប់អណ្តូងមកមើល ព្រោះក្នុងនោះមានពន្យល់លំអិត អំពីអាងចំរោះ ។

គ្រួសារណាក៏ដោយ ក៏អាចតំលើងអាងចំរោះបានដែរព្រោះវាមានភាពងាយស្រួល និងមានលក្ខណៈប្រហាក់ប្រហែលអាងចំរោះសាធារណៈដែរ ។

ហើយបង់តែឬទុកវាឥត្រជាក់ទើបបរិភោគតែម្តង។ ប្រសិនបើបរិភោគទឹកកកយើងត្រូវប្រាកដថាទឹកកកនោះធ្វើពីទឹកស្អាត ។

៥. ទឹក នឹង អនាម័យ

កាលណាប្រជាជនមានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់ គេគប្បីប្រើវាដើម្បីបង្កើនភាពអនាម័យ ដែលវានាំមកឱ្យប្រជាជនវិញនូវសុខភាព។

ដូចបានជំរាបជូនរួចមកហើយការបរិភោគទឹកស្អាតគឺជាកាការពារ កាលរាលដាលនៃជំងឺឆ្លងតាមទឹកមិន ស្អាត។ ទោះជាយ៉ាងណាក៏ដោយ ក៏ជំងឺអាចចំលងមេរោគប្រលាក់តាមដៃឬចានស្លាបព្រា។

ប្រសិនបើមិនបានដុសលាង សំអាតខ្លួនប្រាណឬសំលៀកបំពាក់របស់គេទេ នោះគេនឹងអាចកើតជំងឺសើស្បែក ។ ដូច្នេះត្រូវមានការប្រុងប្រយត្ន័ដូចតទៅ :

- ដុសលាងសំអាតដៃ
- លាងសំអាតដៃក្រោយពេលបត់ជើង
- លាងសំអាតដៃមុនពេលបរិភោគអាហារ
- លាងសំអាតចានស្លាបព្រា
- ងូតទឹកសំអាតខ្លួនប្រាណឱ្យបានទៀងទាត់ សំរាប់អនាម័យផ្ទាល់ខ្លួន
- សំពត់អាវក្រខ្វក់ គប្បីបោកគក់ឱ្យស្អាត

៦. <u>អនាម័យបរិស្ថានផ្សេង១ទៀតដែលត្រូវយកមកពិចារណា</u>

មានអនាម័យបរិស្ថានផ្សេង១ទៀតដែលទាក់ទងទៅនឹងទឹក ហើយត្រូវបានយកមកពិចារណាដូចតទៅ :

- ធ្វើយ៉ាងណាថែរក្សាប្រភពទឹកទាំងឡាយ ឱ្យមានភាពស្អាតជានិច្ចដូចជា ស្ទឹង បឹង ទន្លេ ប្រឡាយ ស្រះ ត្រពាំង អណ្តូងលូនិងអណ្តូងស្នប់ ។

- មិនត្រូវបន្ទោរបង់ ឬ ជុះនោមនៅក្បែរប្រភពទឹកណាមួយឡើយ ។

- ត្រូវដុតសំរាមចោល តែប្រុងប្រយត្ន័នៅពេលដុត ។

- មិនត្រូវដុតវត្ថុអ្វី ដែលធ្វើឡើងដោយការផ្សំជាតិគីមីច្រើនមុខដូចជា ស្បោងប្លាស្ទិក ព្រោះវាអាចបង្កឱ្យមានផ្សែងពុល។

- ត្រូវប្រមូលសំរាមដែលមានជាតិគីមីនេះ យកទៅចោលកន្លែងណាមួយដែលសំរេចដោយប្រធានភូមិ។ ពីព្រោះសំរាមទាំងនោះ វាមិនអាចពុករលួយនៅក្នុងដីបាន ដូចធាតុផ្សំពីសរីរាង្គបានទេហើយវាក៏អាចធ្វើឱ្យប៉ះពាល់ដល់សោភណ័ភាពភូមិបានដែរ ។

រូបភាពខាងក្នុងនៃអាងច្រោះទឹក





ចូរអ្នកលាងដៃ
បន្ទាប់ពី មុនពេល

រូបភាពតម្រូវទិសសំរាប់អនាម័យផ្ទាល់ខ្លួន



បញ្ហា

សក់.សក់ដែលមានចៃអាចបណ្តាល
ឲ្យចៃនោះនៅជាប់និងក្រាស់មានជាតិ
ប្រេងឬក្រាសធុសសក់ ។

ច្រមុះ.ស្បែកច្រមុះខាងក្រៅមានជាតិប្រេងវាអាច
ធ្វើឲ្យស្អុះរន្ធញើស ។

ញើសនិងកន្លែងលាក់កំបាំងញើខ្លាំង
ញើសតែងតែកើតមាននៅកន្លែង
នោះដែលបង្កឲ្យកើតមេរោគៗ
ក្លិនញើសស្អុយក៏បង្កលក្ខណៈងាយ
ស្រួលដល់ការកកើតនៃមេរោគដែរ

ប្រអប់ដៃ.ដៃតែងតែប្រលាក់ដោយសារការកាន់វត្ថុ
ផ្សេងៗដូច្នេះវាក៏អាចធ្វើឲ្យប្រឡាក់ដល់
កន្លែងដទៃទៀតនៃរាងកាយ ជាពិសេស
មាត់និងភ្នែក ។

ម្រាមដៃនិងម្រាមជើង.ញើសតាមក្រលៀត
ម្រាមអាចធ្វើឲ្យស្បែកជ្រាយ បណ្តាល
ឲ្យមេរោគកើតឡើងបាន ។

ក្រចកដៃនិងក្រចកជើង.អាចមក្រចក
និងក្រចក ជាអាហារ ជាជម្រករបស់
មេរោគព្រមទាំងពងសត្វបញ្ញើ(ព្រូន)ទៀតផង ។

ប្រអប់ជើង.ជើងទទេរ កូនព្រូនចង្វាឬមេរោគផ្សេង
ទៀត ដែលនៅលើដីអាចជ្រៀតចូលបានជាពិសេស
នៅក្នុងបង្គន់ ។

ដំណោះស្រាយ

សក់.ត្រូវកក់សំអាតសក់ សិតសក់ និង
ថែរក្សាឲ្យបានស្អាតជានិច្ច
ហើយនៅពេលជាមួយគ្នានោះ ត្រូវពិនិត្យ
មើលក្រែងមានចៃបើមានត្រូវសំអាតវាចេញ ។

ភ្នែក.ដុសលាងជុំវិញភ្នែកដោយប្រុងប្រយ័ត្ន ជា
ពិសេសទារកដើម្បី ជំរះពពិកភ្នែកៗជៀសវាង
ញីភ្នែកដោយដៃឬក្រណាត់កខ្វក់ ។

ស្បែក.ដុសលាងសំអាតឲ្យបានញឹកញាប់
ដើម្បីជំរះញើស ឈាមធូលី ក្រមរស្បែក
របកៗ និងជាតិខ្លាញ់ដោយប្រើសាប៊ូ
និងដើម្បីសំអាតរន្ធញើសបើគ្មានសាប៊ូយើងអាច
ប្រើផេះជំនួសក៏បាន ។

ដៃ.លាងឲ្យស្អាតជាពិសេសនៅមុនពេលរៀបចំម្ហូប
អាហារ មុនពេលបរិភោគអាហារ ក្រោយពេល
បត់ជើង ក្រោយពេលធ្វើការក្នុងច្បារដំណាំ
ក្រោយពេលកាន់ក្រណាត់កខ្វក់ មុនពេលនិង
ក្រោយពេល លាងសំអាតព្យាបាលមុខរបួស
ឬដំបៅ ក្រោយពេលកាន់ឬប៉ះពាល់សត្វ
ពាហនៈ និងក្រោយពេលប៉ះពាល់ជាតិគីមី
ពេលបំពេញការងារឬនៅផ្ទះ ។

ក្រចក.រក្សាភាពស្អាតនិងតម្រឹមឲ្យខ្លីជានិច្ចៗ

ប្រអប់ជើង.ដុសលាងសំអាតឲ្យល្អ និងញើស
នៅចន្លោះម្រាម ហើយទុកវាឲ្យស្ងួតដើម្បី
សំលាប់មេរោគ ។